**JICA Cambodia Office - JICA カンボジア事務所**
May 12 at 3:14 PM ·

[អបអរសាទរទិវាគិលានុបដ្ឋាកអន្តរជាតិឆ្នាំ ២០២៣/ Celebration of International Nurses Day’s Event 2023]
-------------------------------------------
នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ ក្រុមប្រឹក្សាគិលានុបដ្ឋាកកម្ពុជា (CCN) បានរៀបចំអបអរសាទរទិវាគិលានុបដ្ឋាកអន្តរជាតិ ក្រោមប្រធានបទ “វឌ្ឍនភាពរបស់គិលានុបដ្ឋាកជាផ្នែកមួយនៃការអភិវឌ្ឍវិស័យសុខាភិបាល” នៅមន្ទីរពេទ្យជ័យវរ្ម័នទី៧ ក្នុងខេត្តសៀមរាប ក្រោមអធិបតីភាព ឯកឧត្តមសាស្រ្តាចារ្យ ជា គ្រុយ រដ្ឋលេខាធិការក្រសួងសុខាភិបាល ។
ព្រឹត្តិការណ៍នេះមានអ្នកចូលរួមប្រមាណ ៥២៥នាក់ អញ្ជើញមកពីមន្ទីរពេទ្យជាតិ និងឯកជន រួមទាំងអ្នកជំនាញការចៃកា បានចូលរួមអបអរសាទរទិវាគិលានុបដ្ឋាកនេះ និងធ្វើការរួមគ្នាដើម្បីកំណត់ទិសដៅអនាគតនៃគិលានុបដ្ឋាក ដើម្បីបំពេញតម្រូវការសុខភាពសម្រាប់ទាំងអស់គ្នា។
លោកស្រីវេជ្ជបណ្ឌិត HIURA Mizue ប្រធានទីប្រឹក្សាគម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅប្រទេសកម្ពុជា (JICA Strings project) ក៏បានធ្វើបទបង្ហាញលើប្រធានបទ "ផែនការអនាគតសម្រាប់ការបណ្តុះបណ្តាលរបស់គិលានុបដ្ឋាក" ដើម្បីចែករំលែកបទពិសោធន៍ និងការអភិវឌ្ឍវិជ្ជាជីវៈបន្ថែមទៀត ដែលជាគោលដៅចម្បងនៃព្រឹត្តិការណ៍ដ៏ពិសេសនេះ៕
អត្ថបទ៖ អ៊ឹង សុដាវី មន្ត្រីកម្មវិធីទទួលបន្ទុកផ្នែកសុខាភិបាល ការិយាល័យចៃកាប្រចាំប្រទេសកម្ពុជា និងក្រុមការងារគម្រោង Strings

On 12th May, the Cambodian Council of Nurses (CCN) organized the 2023 International Nurses Day’s Event under the theme, “Our Nurses, Our Future” at Jevaraman 7th Hospital in Siem Reap presided over by H.E. Prof. Thea Kruy, Secretary of State, Ministry of Health.
Approximately 525 participants from public and private hospitals including JICA experts, participated in the event to celebrate nurses and work together to chart the future direction of nursing to meet the needs of Health for All.
Dr. HIURA Mizue, Chief Advisor of the Project for Strengthening In-Service Training System in Cambodia (Strings Project), has presented the presentation on the topic of “Future Plan for in-service training for nurses” for sharing experiences and further professional development which were the main goals of this special event.
Creditor: Oeng Sodavy, Health Sector, JICA Cambodia Office and Strings Project team






